**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

# សូមគោរពជូន

## លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

## និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

**តាមរយៈ:** លោកជំទាវ ឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ

**កម្មវត្ថុ** ៖ របាយការណ៍ជំនួបពិភាក្សាការងារ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រវាង **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ជាមួយ **ឯកឧត្តម** DOMINIC WILLIAMS ឯកអគ្គរាជទូត នៃចក្រភពអង់គ្លេស ប្រចាំព្រះរាជាណាចក្រកម្ពុជា ។

ថ្ងៃពុធ មួយកើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៤ វេលាម៉ោង ០៩:០០ នាទីព្រឹក នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ បានទទួលជួបពិភាក្សាជាមួយ **ឯកឧត្តម** DOMINIC WILLIAMS ឯកអគ្គរាជទូត នៃចក្រភពអង់គ្លេស ប្រចាំព្រះរាជាណាចក្រកម្ពុជា និងសហការី រួមមាន៖

១. Mr. Rob Clark ( Regional Coordinator of Serious and Organised Crime )

២. Mr. PETTER VERNON ( International Liaison Officer )

៣. Mr. WILL SYKES ( Fiscal Crime Liaison Officer )

៤. Mr. SIENG VANTHA មន្ត្រីនយោបាយ និងសិទ្ធិមនុស្ស ( UK Embassy )

**ភាគីអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**

១. ឯកឧត្តម ឧត្តមសេនីយ៍ទោ នី គឹមស្រេន អគ្គលេខាធិការរង គ.ជ.ប.ជ

២. លោក ឧត្តមសេនីយ៍ទោ ហាង ជីវ័ន្ត ប្រធានលេខាធិការដ្ឋានរដ្ឋបាល សរុប

៣. លោក ឧត្តមសេនីយ៍ទោ រ៉ន សុភ័ក្ត្រវឌ្ឍនា ប្រធានក្រុមជំនួយកិច្ចការបង្ការទប់ស្កាត់

៤. លោក ឧត្តមសេនីយ៍ទោ អ៊ុំ កាមិន្ទ អនុប្រធានលេខាធិការដ្ឋានរដ្ឋបាល សរុប

កិច្ចជំនួបពិភាក្សា ត្រូវបានលើកឡើងទាក់ទងបញ្ហាជួញដូរមនុស្ស នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ រហូតមានការដាក់ទណ្ឌកម្មទៅលើក្រុមហ៊ុន និងមនុស្សមួយចំនួន ដូចជាប្រទេសថៃ មីយ៉ាន់ម៉ា កម្ពុជា ឡាវ ជាដើម ដូច្នេះ គឺមានគោលបំណងស្វែងរកឲ្យបានច្បាស់លាស់ តាមរយៈកិច្ចសហប្រតិបត្តិការជាមួយគ្នា ដើម្បីឆ្លើយតបចំពោះបញ្ហានេះនៅប្រទេសកម្ពុជា ក៏ដូចជាការចែករំលែកបទពិសោធន៍ទៅវិញទៅមក ។

ជាកិច្ចចាប់ផ្តើម **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានប្រសាសន៍ថ្លែងអំណរគុណចំពោះវត្តមានរបស់ ឯកឧត្តម ឯកអគ្គរាជទូត នៃចក្រភពអង់គ្លេស ក៏ដូចជាអ្នកជំនាញ លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងឱកាសជួបពិភាក្សាការងារនៅថ្ងៃនេះ ។ លោកជំទាវ មានប្រសាសន៍បន្តថា កន្លងមកកម្ពុជាធ្លាប់ប្រឈមជាមួយបញ្ហាជួញដូរមនុស្ស ហើយយើងព្រួយបារម្ភចំពោះប្រជាជនកម្ពុជាដែលបានធ្វើចំណាកស្រុកទៅក្រៅប្រទេស ក៏នៅមិនទាន់រកដំណោះស្រាយដើម្បីឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស ជួញដូរពលកម្ម ជួញដូរផ្លូវភេទបានល្អប្រសើរនៅឡើយ ។ កាលពីចុងឆ្នាំ២០២២ មានព័ត៌មានបានផ្សព្វផ្សាយថា មានបទល្មើសជួញដូរមនុស្សកើតឡើងនៅក្នុងប្រទេសកម្ពុជា ដែលភាគច្រើនបានកើតមានចំពោះជនបរទេស ហើយយើងក៏បានបើកប្រតិបត្តិការដើម្បីស្វែងរកបទល្មើសទាំងនោះផងដែរ នៅពេលនោះ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានអនុញ្ញាតិឲ្យប្រើប្រាស់បណ្តាញសង្គម(Facebook Page) ដើម្បីទទួលពាក្យបណ្តឹង ឬការរាយការណ៍ណាមួយពីមហាជន ឬអ្នកដែលបានដឹងអំពីព័ត៌មានទាន់ហេតុការណ៍ នៃបទល្មើសទាំងនោះដើម្បីធ្វើប្រតិបត្តិការទាន់ពេលវេលា ក្រោយពីមានការបង្ក្រាបទើបយើងដឹងថា ជនរងគ្រោះ និងជនប្រព្រឹត្តបទល្មើស គឺមានសញ្ជាតិដូចគ្នា យើងក៏បានដាក់ជាសំណួរថា ហេតុអ្វីបានជាមានជនបរទេសមកធ្វើការនៅកម្ពុជាហើយបានបង្កើតឡើងនូវបញ្ហានេះឡើង? យើងក៏ដឹងដែរថាក្នុងឆ្នាំ២០២០-២០២១ គឺជាអំឡុងពេល នៃការរីករាលដាល នៃជំងឺកូវីដ១៩ ប្រទេសជិតខាងបានប្រកាសបិទព្រំដែន ប៉ុន្តែនៅតែមានប្រជាពលរដ្ឋបានចូលមកប្រមាណជាង ៣០ម៉ឺននាក់ ពេលនោះយើងមិនគិតអំពីផ្លូវច្បាប់ទេ ពីព្រោះយើងត្រូវមានកាតព្វកិច្ចក្នុងការជួយសង្គ្រោះ ដោយយកពួកគាត់មកស្នាក់នៅកន្លែងដែលមានសុវត្ថិភាព ពេលនោះក៏មានជនបរទេសបានចូលមកកម្ពុជាផងដែរ ។ បន្ទាប់ពីជំងឺកូវីដ១៩ លែងកើតមាន កម្ពុជាបានធ្វើការផ្សព្វផ្សាយ និងលើកទឹកចិត្តដល់អ្នកវិនិយោគបង្កើននូវកម្មវិធីស្តារសេដ្ឋកិច្ចរបស់គាត់ឡើងវិញ ចំពោះរាជរដ្ឋាភិបាលកម្ពុជា ពុំដែលមានចេតនាក្នុងការបង្កើតឡើងនូវបទឧក្រិដ្ឋណាមួយនៅក្នុងប្រទេសខ្លួនឯងទេ ផ្ទុយទៅវិញយើងបានស៊ើបអង្កេត បង្ក្រាប ប៉ុន្តែអ្វីដែលជាបញ្ហា គឺ Online យើងធ្លាប់បានចុះធ្វើអធិការកិច្ចជាច្រើន យើងនៅតែមិនដឹងថាគេបានធ្វើអ្វីខ្លះ ពីព្រោះពួកគេអង្គុយតែនៅមុខកុំព្យូទ័រ នៅពេលដែលយើងបានរកឃើញព័ត៌មានដែលលេចចេញនូវភាពមិនប្រក្រតីតាមប្រព័ន្ធ Online ទើបយើងចាប់ផ្តើមស្រាវជ្រាវ ចាប់ពីខែសីហា រហូតដល់ដើមឆ្នាំ២០២៤ គឺមានជាង ១០០០ ករណីដែលយើងរកឃើញ ប៉ុន្តែក្នុងឆ្នាំ២០២៣ ក៏មានព័ត៌មានមួយចំនួនប្រហែល ៨០% មិនពិតប្រាកដ ចំពោះករណីមិនពិតប្រាកដនេះ គឺជាករណីដែលផ្តល់ព័ត៌មាន មិនចង់ធ្វើការនៅកន្លែងនោះបន្តទៀតដោយចង់ផ្លាស់ប្តូរកន្លែងធ្វើការដោយមិនទាន់ចប់កិច្ចសន្យា ហើយមានករណីខ្លះទៀតគឺជាករណីយុវជនដើរត្អូញត្អែរដើម្បីឲ្យអ្នកផ្ទះ ឬក្រុមគ្រួសារផ្ញើលុយមកខ្លួនតែប៉ុណ្ណោះ និងមានករណីមិនពិតជាច្រើនទៀត ប៉ុន្តែក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ទទួលស្គាល់ថាពិតជាមានបទល្មើសដែលពាក់ព័ន្ធជាមួយ Game Scam អំពើជួញដូរមនុស្សកើតមាននៅកម្ពុជាពិតប្រាកដមែន ។ លោកជំទាវ មានប្រសាសន៍បញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជា មិនអនុញ្ញាតិឲ្យកើតមាន Scam Center នៅក្នុងប្រទេសកម្ពុជាទេ អ្វីដែលពិបាកសម្រាប់យើង គឺពួកគេបានប្រើប្រាស់ទីតាំងមួយចំនួនសម្រាប់ប្រព្រឹត្តបទល្មើស ដោយការស្នើសុំបើកអាជីវកម្មស្របច្បាប់ហើយបង្កប់បទល្មើសនៅពីក្រោយ ធ្វើឲ្យយើងពិបាកក្នុងការចូលទៅដល់ ជឿជាក់ថា អ្នកបញ្ជាផ្នែកប្រតិបត្តិការ Online (Operator) មិនមែននៅក្នុងប្រទេសកម្ពុជាទេ គឺពួកគេមានបណ្តាញចាត់តាំង

ច្បាស់លាស់ ពីព្រោះយើងបានធ្វើការតាមដានករណីស្ត្រីខ្មែរបានរងគ្រោះនៅក្នុងប្រទេសឡាវ គឺប្រភពថវិការបស់ជនល្មើសត្រូវបានផ្ទេរចូលទៅតាមធនាគារជាច្រើននៅលើពិភពលោក ចំពោះករណីនេះ យើងទទួលស្គាល់ថា កម្ពុជានៅមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ ដើម្បីធ្វើការគ្រប់គ្រងប្រព័ន្ធឌីជីថលនេះបានទេ ប៉ុន្តែយើងបានរកឃើញករណីជាច្រើនបានប្រើប្រាស់គណនីមិនពិតប្រាកដ(Fake Account) ។ កម្ពុជា តែងតែអំពាវនាវដល់បណ្តាស្ថានទូតប្រទេសជាមិត្តពាក់ព័ន្ធទាំងអស់ សូមចូលរួមសហការក្នុងការទទួលខុសត្រូវ ដើម្បីធ្វើការទប់ស្កាត់ចំពោះការធ្វើចំណាកស្រុករកការងារធ្វើរបស់ប្រជាពលរដ្ឋរបស់ខ្លួននៅក្រៅប្រទេស ពីព្រោះគាត់អាចក្លាយជាជនរងគ្រោះដោយអំពើជួញដូរមនុស្សក៏ថាបាន ហើយចំពោះកម្ពុជាក៏មានពលរដ្ឋបានរងគ្រោះនៅឯក្រៅប្រទេសផងដែរ ពេលដែលគាត់បានរងគ្រោះទើបគាត់ហៅឲ្យជួយ គឺជិតហួសពេលក្នុងការជួយសង្គ្រោះគាត់ ប៉ុន្តែកម្ពុជានៅតែជួយឲ្យគាត់ត្រឡប់មកវិញ អ្វីដែលសំខាន់កម្ពុជា សូមស្នើដល់ប្រទេសពាក់ព័ន្ធទាំងអស់សហការ និងរកវិធានការដើម្បីទប់ស្កាត់ទាំងអស់គ្នា ហើយចំពោះវិធានការការពារ តើយើងគួរមានវិធានការដោយរបៀបណា មធ្យោបាយ ឬយុទ្ធសាស្ត្រណាខ្លះ? យើងត្រូវទទួលស្គាល់ថា បទល្មើសជួញដូរមនុស្សមិនមែនកើតមានតែនៅប្រទេសកម្ពុជាតែមួយទេ គឺកើតមានរាយប៉ាយនៅតាមបណ្តាប្រទេសទាំងអស់ ពីព្រោះជនល្មើស មានបណ្តាញគ្រប់ប្រទេសក្នុងពិភពលោក កន្លែងណាមានការធ្វេសប្រហែស គេនឹងប្រព្រឹត្តនៅកន្លែងនោះ ។ **លោកជំទាវ** មានប្រសាសន៍ស្នើទៅបណ្តាប្រទេសពាក់ព័ន្ធទាំងឡាយសូមកុំផ្តោតមកលើកម្ពុជា ថាជាទីតាំងសម្រាប់ជួញដូរមនុស្ស ឬជាកន្លែងបង្ខាំងមនុស្សរាប់សិបម៉ឺននាក់ តើមនុស្សទាំងនោះនៅកន្លែងណាខ្លះ? យើងគួរតែសហការគ្នារកដំណោះស្រាយ រកវិធាននការទប់ស្កាត់ ពីព្រោះជនល្មើសមានរចនាសម្ព័ន្ធប្រទាក់ក្រឡាគ្នាពេញពិភពលោក ករណីនេះ UNODC បានលើកឡើងថាមានជនរងគ្រោះ ១០ម៉ឺននាក់ ចំណែកប្រទេសឥណ្ឌូនេស៊ី និងតៃវ៉ាន់ ក៏បានលើកអំពីបញ្ហានេះផងដែរ ប៉ុន្តែស្ថានទូត នៃបណ្តាប្រទេសពាក់ព័ន្ធទាំងនេះ គឺបានសហការ និងបានអរគុណកម្ពុជាថាបានសង្គ្រោះប្រជាពលរដ្ឋរបស់គាត់ ហើយអ្វីដែលមិនមែនការពិត គឺចំនួនជនរងគ្រោះច្រើន ពីព្រោះកម្ពុជា ជាប្រទេសតូច ការវិនិយោគក៏មិនមានចំនួនច្រើន យើងអាចធ្វើការគ្រប់គ្រងជនបរទេសដែលចូលមកកម្ពុជាបាន យើងទទួលស្គាល់ថាមានជនរងគ្រោះចំនួនតិចតួច ហើយក៏មិនមែនពាក់ព័ន្ធអំពើជួញដូរមនុស្សទាំងអស់ដែរ អ្វីដែលកម្ពុជាព្រួយបារម្ភ គឺភាពរឹងមាំផ្នែកច្បាប់ និងបច្ចេកទេសក្នុងការគ្រប់គ្រងបញ្ហា Game Scam ឬល្បែងអនឡាញមួយចំនួនទៀត ពីព្រោះកម្ពុជាមិនបានអនុញ្ញាតឲ្យបើកដាច់ខាត កន្លងមកយើងបានធ្វើការត្រួតពិនិត្យទីតាំងល្បែងអនឡាញដែលមានអាជ្ញាប័ណ្ណទាំងអស់ ហើយបានបិទប្រហែលចំនួន ៥០% ដោយមិនមានភាពប្រក្រតី ត្រឹមត្រូវតាមគោលការណ៍រាជរដ្ឋាភិបាល យើងបានបង្កើតគណៈកម្មាធិការសន្តិសុខឌីជីថល ដែលដឹកនាំដោយ **ឯកឧត្តមសន្តិបណ្ឌិត នេត សាវឿន ឧបនាយករដ្ឋមន្ត្រី** ក្នុងការដឹកនាំ គ្រប់គ្រងប្រព័ន្ធឌីជីថលបានមួយផ្នែក ប៉ុន្តែទោះជាយ៉ាងណាកម្ពុជា នៅតែត្រូវការជំនួយបច្ចេកទេសពីបណ្តាប្រទេសធំៗ និងជាប្រទេសមានបទពិសោធន៍ដើម្បីឲ្យគណៈកម្មាធិការសន្តិសុខឌីជីថលអាចអនុវត្តបាន និងមានប្រសិទ្ធភាពខ្ពស់ទាំងនៅក្នុងប្រទេស និងជាមួយបណ្តាប្រទេសនៅក្នុងពិភពលោក សព្វថ្ងៃកម្ពុជា កំពុងសិក្សាអំពីវិធីសាស្ត្រក្នុងការគ្រប់គ្រងលំហូរជនទេសន្តរប្រវេសន៍ឆ្លងកាត់ព្រំដែន ពីព្រោះកម្ពុជាមានច្រកព្រំដែនជាច្រើនជាមួយប្រទេសជិតខាងទាំងច្រកអន្តរជាតិ ច្រករបៀង និងមានច្រកធម្មជាតិ(ច្រកសម័យជូនតា) ដូច្នេះហើយទើបកម្ពុជា ចាំបាច់ត្រូវមានវិធានការក្នុងការគ្រប់គ្រងផ្នែកច្បាប់ចំពោះជនទេសន្តរប្រវេសន៍ចេញចូល ដើម្បីប្រកបរបររកស៊ី ឬធ្វើការងារ ជាពិសេស គឺដើម្បីគ្រប់គ្រងការហូរចូលជនបរទេសដែលមកធ្វើការ

នៅកម្ពុជា ។ លោកជំទាវ បានមានប្រសាសន៍ថា គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កំពុងរៀបចំផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ ២០២៤-២០២៨ លើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នឹងប្រកាសផ្សព្វផ្សាយនៅក្នុងខែមិថុនាខាងមុខនេះ ដែលយើងមានយុទ្ធសាស្ត្រ ចំនួន៤ ធំៗ គឺ (១.ការបង្ការទប់ស្កាត់ ២. ការអនុវត្តច្បាប់ យុត្តិធម៌ព្រហ្មទណ្ឌ ៣.កិច្ចការពារជនរងគ្រោះ ៤.កិច្ចសហប្រតិបត្តិការ និងនីតិវិធីច្បាប់) យើងក៏បានដាក់ចេញនូវវិធានការមួយចំនួនផងដែរសម្រាប់អនុវត្តឲ្យមានប្រសិទ្ធភាព អ្វីដែលកម្ពុជាបានគិត គឺការបណ្តុះបណ្តាលជំនាញដល់ប្រជាពលរដ្ឋ ជាពិសេសយុវជន និងផ្តល់ការងារធ្វើនៅក្នុងស្រុកទៅតាមជំនាញរបស់គាត់ ជៀសវាងបណ្តោយឲ្យពួកគាត់ធ្វើចំណាកស្រុកទៅរកការងារធ្វើនៅក្រៅប្រទេស យើងមិនចង់រង់ចាំគាត់រងគ្រោះហើយបានជួយសង្គ្រោះនោះទេ យើងចង់ការពារពួកគាត់មិនឲ្យ រងគ្រោះតែម្តង អ្វីដែលជាភាពប្រឈម គឺការផ្លាស់ប្តូរឥរិយាបថ ឬទម្លាប់ដែលមាននៅក្នុងគំនិតរបស់ពួកគាត់ ប៉ុន្តែចាំបាច់ត្រូវតែធ្វើ ។ **លោកជំទាវ** មានប្រសាសន៍បញ្ជាក់ថា មិនអាចក្រសួង ស្ថាប័នណាមួយ ឬប្រទេសណាមួយ អាចធ្វើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តែឯងបានទេពីព្រោះមានការទំនាក់ទំនងលើវិស័យជាច្រើនចំពោះបទល្មើសនេះ ដោយកន្លងមកក្រសួងស្ថាប័នបានធ្វើការងារនេះដោយឡែកៗពីគ្នា ប៉ុន្តែមិនទទួលបានជោគជ័យទេ ពីព្រោះជនល្មើសមានបណ្តាញច្រើនអាចប្រព្រឹត្តបានគ្រប់ពេល គ្រប់កន្លែងប្រសិនបើមានចន្លោះប្រហោង ហេតុដូចនេះ ទើបរាជរដ្ឋាភិបាលកម្ពុជា បានសម្រេចបង្កើតគណៈកម្មាធិការជាតិ ដោយមានក្រសួងស្ថាប័នចម្រុះ មកធ្វើការងារជាមួយគ្នាលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បច្ចុប្បន្ននេះមានចំនួន ២២ក្រសួង ស្ថាប័ន និង៥អង្គភាពជាសមាជិក យើងមាន ៦ ក្រសួង ស្ថាប័ន ជាអនុប្រធានដែលដឹកនាំការងារជំនាញទាំង៦ នៅថ្នាក់ជាតិមានអគ្គលេខាធិការដ្ឋាន ០១ ដឹកនាំអនុវត្តដោយ លោកជំទាវ ផ្ទាល់ ជាអនុប្រធានអចិន្ត្រៃយ៍ នៅថ្នាក់ក្រោមជាតិមាន អភិបាល នៃគណៈអភិបាលរាជធានី/ខេត្ត ជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស រាជធានី/ខេត្ត ចំពោះការទំនាក់ទំនងលក្ខណៈអន្តរជាតិ គឺយើងធ្វើការជាមួយបណ្តាស្ថានទូត ស្ថានតំណាង នៃប្រទេសពាក់ព័ន្ធ និងស្ថានទូត ឬនិវេសនដ្ឋានកម្ពុជាប្រចាំនៅឯក្រៅប្រទេស យើងមានអនុស្សរណៈយោគយល់គ្នា MOU, SOP ជាមួយបណ្តាប្រទេសនៅក្នុងតំបន់ និងពិភពលោក ក៏ដូចជាអង្គការដៃគូជាតិ អន្តរជាតិមួយចំនួនទៀតផងដែរ ទោះបីជាយើងមានរចនាសម្ព័ន្ធទាំងនេះក្តី ក៏យើងមិនទាន់មានបណ្តាញការងារ និងការទំនាក់ទំនងគ្នាមិនទាន់បានល្អ ដូចបណ្តាញជនល្មើសទេ ដោយសារក្រសួង ស្ថាប័ន និងបណ្តាប្រទេសជាច្រើន ចង់ធ្វើការងារនេះដោយឡែក និងចាត់ទុកថាកិច្ចសហការមិនសំខាន់ ម្នាក់ៗច្រើនតែចង្អុលដាក់គ្នាជាងការបង្កើនកិច្ចសហការ ប៉ុន្តែសម្រាប់កម្ពុជា គិតថាការពង្រឹងកិច្ចសហការតែមួយគត់ដែលអាចយកជោគជ័យលើជនល្មើសបាន យើងត្រូវតែរួមគ្នាគិត និងជួយគ្នាទៅវិញទៅមក ដើម្បីរកដំណោះស្រាយចំពោះបញ្ហាទាំងនេះ កម្ពុជារង់ចាំអនុសាសន៍ល្អៗពី ឯកឧត្តម ក៏ដូចជាអ្នកជំនាញទាំងអស់ក្នុងផ្តល់នូវបទពិសោធន៍ ឬវិធានការ តើយើងគួរដោះស្រាយយ៉ាងដូចម្តេច?

Mr. Rob Clark: Regional Coordinator of Serious and Organised Crime នៃចក្រភពអង់គ្លេស មានមតិថ្លែងអំណរគុណចំពោះព័ត៌មានដែល លោកជំទាវ បានលើកឡើងច្បាស់លាស់អំពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ក៏ដូចជាបញ្ហា Scam Center ហើយយើងបានធ្វើការសិក្សាច្រើនជាពិសេសនៅប្រទេសម៉ាឡេស៊ី មីយ៉ាន់ម៉ា និងឡាវ ពាក់ព័ន្ធបញ្ហាទាំងអស់នេះ ។ សូមឯកភាពចំពោះការលើកឡើងរបស់ លោកជំទាវ

អំពីការបង្កើតយន្តការបង្ការទប់ស្កាត់ យើងពិតជាត្រូវការយន្តការ វិធានការសម្រាប់ថ្នាក់តំបន់មួយ ដើម្បីដោះស្រាយបញ្ហានេះ ពីព្រោះសកម្មភាពនេះ អាចមានការផ្លាស់ប្តូរពីកន្លែងទៅកន្លែងមួយផ្សេងទៀតបានយ៉ាងងាយស្រួល និងឆាប់រហ័ស បច្ចុប្បន្ននេះ រាជរដ្ឋាភិបាល នៃចក្រភពអង់គ្លេស កំពុងសិក្សាបង្កើតឲ្យមានយន្តការបង្ការទប់ស្កាត់ សម្រាប់ថ្នាក់តំបន់មួយដែលមានសក្តានុពលអាចអនុវត្តបាននៅទូទាំងអាស៊ីអាគ្នេយ៍ផងដែរ ទាក់ទងនឹងបញ្ហានេះក្រុមការងារមានចំណាប់អារម្មណ៍ក្នុងការសហការជាមួយប្រទេសកម្ពុជាផងដែរ ហើយយើងរីករាយក្នុងការចែករំលែកនូវបទពិសោធន៍ និងការយល់ដឹងរបស់យើង ទាក់ទងនឹងការងារប្រតិបត្តិការក្នុងការបង្ក្រាបបញ្ហាទាំងអស់នោះ ។ ចំពោះការងារនេះផងដែរយើងបានធ្វើការជាមួយមន្ត្រីជាន់ខ្ពស់អាស៊ាន លើបញ្ហាជួញដូរមនុស្សជាពិសេសចង់បង្កើតឲ្យមានក្រុមការងារដែលមើលទៅលើលំហូរហិរញ្ញវត្ថុ នៃបញ្ហាទាំងអស់នេះ ។

Mr. PETTER VERNON ( International Liaison Officer ) មានមតិចូលរួមថា រាល់ចំណុចដែល លោកជំទាវ បានលើកឡើងទាំងអស់ គឺពិតជាការព្រួយបារម្ភរបស់កម្ពុជា អ្វីដែលយើងចង់និយាយ គឺការលើកឡើងរបស់លោកជំទាវ ពាក់ព័ន្ធផ្នែកច្បាប់ សម្រាប់រាជរដ្ឋាភិបាលចក្រភពអង់គ្លេសមានទីភ្នាក់ងារទទួលបន្ទុកផ្នែកឧក្រិដ្ឋកម្ម និងមានការប្តេជ្ញាចិត្តជួយកម្ពុជា ជាពិសេសទៅលើបញ្ហាដែលទើបកើតឡើងថ្មីៗនេះ ដូច្នេះអ្វីដែលយើងអាចធ្វើបាន គឺការចែករំលែកចំណេះដឹង ជំនាញ និងបទពិសោធន៍របស់យើង តាមរយៈកិច្ចសហការទ្វេភាគី ឬពហុភាគី រួមបញ្ចូលទាំងការផ្តល់ព័ត៌មានគ្នាទៅវិញទៅមក ការបណ្តុះបណ្តាលសមត្ថភាព រួមទាំងបញ្ហាឌីជីថលផងដែរ ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជា មានតម្រូវការ បញ្ហាណាមួយសូមផ្តល់ព័ត៌មានមក យើងខ្ញុំរីករាយក្នុងការពិចារណារបស់កម្ពុជា ។

Mr. WILL SYKES ( Fiscal Crime Liaison Officer) បានលើកឡើងថា ពីខាងចំណូល និងសារពើពន្ធនៃចក្រភពអង់គ្លេស បានពិនិត្យទៅលើហិរញ្ញវត្ថុ និងលំហូរហិរញ្ញវត្ថុខុសច្បាប់ ដែលទាំងអស់នេះ គឺជាបញ្ហាមួយថ្មី ហើយជនល្មើសបានដើរមុនយើងមួយជំហាន ។

**ឯកឧត្តម** DOMINIC WILLIAMS (UK Embassy) មានមតិលើកឡើងថា អរគុណចំពោះការផ្តល់ព័ត៌មានយ៉ាងក្បោះក្បាយរបស់ លោកជំទាវ អំពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក៏ដូចជាបទល្មើសតាមប្រព័ន្ធអនឡាញ ។ ឯកឧត្តម បានបន្តថា ដូចដែល លោកជំទាវ បានជ្រាបហើយថា យើងបានដាក់ទណ្ឌកម្មទៅលើក្រុមហ៊ុនមួយចំនួន ក្នុងគោលបំណងគាំទ្រដល់ការងាររបស់រាជរដ្ឋាភិបាល ដែលយើងគិតថាការដាក់ទោសទណ្ឌគឺជាការផ្លាស់ប្តូរឥរិយាបថរបស់ជនល្មើសទាំងនោះ ហើយសម្រាប់អាជីវកម្ម និងជនជាតិទាំងអស់នោះ ក៏មានជនជាតិខ្មែរ និងមានជនបរទេសមានសញ្ជាតិខ្មែរផងដែរ និងមានការចោទប្រកាន់ក្រុមហ៊ុនមួយចំនួនដែលមានការពាក់ព័ន្ធនឹងបទល្មើសនេះ តាមរយៈការដាក់ទណ្ឌកម្ម សង្ឃឹមថាក្រុមហ៊ុនមួយចំនួនមានការពិចារណាឡើងវិញចំពោះការចូលរួមក្នុងបទល្មើសទាំងនេះ ហើយក៏ជាការផ្ញើសារទៅកាន់វិនិយោគិន ម្ចាស់អាជីវកម្មទាំងអស់ថាយើងនៅតែបន្តតាមដាន ហើយចំពោះភស្តុតាងដែលយើងយកមកសំអាង គឺមិនខ្ពស់ដូចភស្តុតាងដែលយើងយកទៅតម្កល់នៅតុលាការទេ ដូច្នេះតាមរយៈការដាក់ទណ្ឌកម្ម គឺអាចជួយដល់ការងារបង្ការទប់ស្កាត់ នៃអំពើជួញដូរមនុស្សរបស់រាជរដ្ឋាភិបាលកម្ពុជា ។

**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មានប្រសាសន៍ថ្លែងអំណរគុណចំពោះការលើកឡើងរបស់ ឯកឧត្តម ឯកអគ្គរាជទូតចក្រភពអង់គ្លេស និងក្រុមការងារ

ដែលបានលើកឡើងនូវចំណុចសំខាន់ជាច្រើន ក្នុងនាមក្រសួងមហាផ្ទៃ និងក្នុងនាមគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស មានសេចក្តីរីករាយជាខ្លាំង កម្ពុជាក៏កំពុងតែរិះរកមធ្យោបាយដើម្បីឈានទៅរកការលប់បំបាត់អំពើជួញដូរមនុស្ស និងមានការងារមួយចំនួនទៀតដែលកម្ពុជាធ្វើតែឯងមិនបានទេ គឺត្រូវពឹងផ្អែកលើជំនួយតាមរយៈកិច្ចសហការពីខាងក្រៅ និងសូមអរគុណចំពោះរាជរដ្ឋាភិបាលចក្រភពអង់គ្លេស ដែលបានជួយលើការងារនេះ យើងខ្ញុំមិនភ្លេចទេថា ចក្រភពអង់គ្លេស គឺជាអ្នកចេញច្បាប់មុនគេក្នុងការប្រយុទ្ធប្រឆាំងទាសភាពសម័យទំនើប បន្ទាប់មក គឺប្រទេសអូស្ត្រាលី ដែលយើងខ្ញុំក៏បានចូលរួមផ្សព្វផ្សាយច្បាប់នេះផងដែរ ។ លោកជំទាវ មានប្រសាសន៍បន្តថា បើគ្មានការជួយពីមជ្ឈដ្ឋានខាងក្រៅទេ ឧក្រិដ្ឋជននៅតែមានសក្តានុពលក្នុងការប្រព្រឹត្តបទល្មើសដែលធ្វើឲ្យយើងពិបាកក្នុងការបង្ក្រាប ដូច្នេះការលើកឡើងរបស់ ឯកឧត្តម និងក្រុមការងារ គឺពិតជាបានផ្តល់នូវមតិយោបល់ល្អក្នុងការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបទល្មើសតាមប្រព័ន្ធអនឡាញ ក្នុងនាមគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលជាសេនាធិការជូនរាជរដ្ឋាភិបាលកម្ពុជា និងទទួលបានគោលការណ៍ពីថ្នាក់ដឹកនាំថា រាជរដ្ឋាភិបាលកម្ពុជា មិនដែលគាំទ្រចំពោះបទល្មើសណាមួយឲ្យកើតមាននៅក្នុងប្រទេសកម្ពុជាឡើយ ដូច្នេះ យើងទាំងអស់គ្នាធ្វើយ៉ាងណាឲ្យបទល្មើសទាំងអស់នេះរលុបបាត់ចេញពីកម្ពុជា ។ ដូច ឯកឧត្តម និងក្រុមការងារបានជ្រាបមកហើយថា កម្ពុជា គឺជាប្រទេសតូចមួយដែលទើបងើបពីសង្គ្រាម ក៏ដូចជាគ្រោះមហន្តរាយជាច្រើន ហើយកំពុងព្យាយាមធ្វើឲ្យខ្លួនឯងឈរលើគោលការណ៍មួយ ឆ្ពោះទៅរកការអភិវឌ្ឍន៍ និងសន្តិភាព ហើយការប្រកួតប្រជែងផ្នែកសេដ្ឋកិច្ចនៅមានកម្រិតនៅឡើយ ហេតុនេះហើយបានជាយើងខ្ញុំត្រូវការពឹងផ្អែកលើប្រទេសដែលមានឥទ្ធិពល និងមានបទពិសោធន៍ខ្ពស់ក្នុងការជួយយើងខ្ញុំ ដើម្បីធ្វើឲ្យដំណោះស្រាយនេះដំណើរការដោយល្អប្រសើរ ដោយជឿជាក់ថា ចក្រភពអង់គ្លេស ក៏មានបំណងក្នុងការចូលរួមចំណែកក្នុងការទប់ស្កាត់អំពើជួញដូរមនុស្សផងដែរ ។ ដូច្នេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមក្រសួងមហាផ្ទៃ យើងខ្ញុំហ៊ានអះអាងថា កម្ពុជា នឹងចូលរួមក្នុងសកម្មភាពទាំងឡាយណាដែលនាំឆ្ពោះឲ្យមានសន្តិសុខពិភពលោក ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើសូម **លោកជំទាវ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជា អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ ។

ថ្ងៃចន្ទ ៦កើត ខែខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៤

**អ្នកធ្វើរបាយការណ៍**

វរសេនីយ៍ឯក សៅ ស៊ីនួន

21/05/24

**គោរពជូន**

**លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់។

ថ្ងៃចន្ទ ១៣កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៤

**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯក វេជ្ជ.ប៊ុណ្ណា សំខាន់